**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សម្តេចពិជ័យសេនា ទៀ បាញ់**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ជូនចំពោះ**

**ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានស្ថាប័ន មេបញ្ជាការគ្រប់កងឯកភាព**

**នាយទាហាន នាយទាហានរង និងពលទាហាន**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់**

ជាបឋម ខ្ញុំនិងភរិយា សូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់** ដែលបានផ្ញើសារលិខិតអំណរសាទរដ៏កក់ក្តៅបំផុត ក្នុងឱកាសដែលរូបខ្ញុំ បានទទួលនូវគោរមងារជា **សម្តេចពិជ័យសេនា ទៀ បាញ់** ដែលជាការប្រោសប្រទានដ៏ឧត្តុង្គឧត្តមនៃ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

ដើម្បីឲ្យសក្តិសមទៅនឹងព្រះរាជគោរមងារដ៏វិសេសវិសាលនេះ ខ្ញុំសូមសន្យាថា នឹងខិតខំបំពេញភារកិច្ចដឹកនាំវិស័យការពារជាតិ ឲ្យអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញា ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ពិសេសការកែទម្រង់កង-យោធពលខេមរភូមិន្ទ ឲ្យស្របទៅនឹងការរីកចម្រើនរបស់ប្រទេសជាតិ និងពិភពលោក ដែលជាកងកម្លាំងមានឧត្តមគតិស្មោះត្រង់ដាច់ខាតចំពោះជាតិមាតុភូមិ គោរពស្រឡាញ់ប្រជាជន មានឆន្ទៈប្រយុទ្ធប្តូរផ្តាច់ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការការពារឯករាជ្យ សន្តិភាព អធិបតេយ្យ បូរណភាពទឹកដី និងធានាឲ្យបាននូវសុខសន្តិភាព និងស្ថិរភាពនយោបាយ ដែលជាមូលដ្ឋានគ្រឹះ សម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិ ឲ្យកាន់តែរីកចម្រើនលើគ្រប់វិស័យថែមទៀត ។

ខ្ញុំសូមជូនពរ **ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់** សូមប្រកបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសូមសម្រេចបានជោគជ័យគ្រប់ភារកិច្ចក្នុងការបម្រើជាតិមាតុភូមិនៃយើង ។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃកងយោធពលខេមរភូមិន្ទ ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧

**ទៀ បាញ់**